# អនុសញ្ញាទីក្រុងរ៉ូម ១៩៦១
# អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារ
# អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ

ធ្វើនៅទីក្រុងរ៉ូម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៦១

**មាតិកា***


មាត្រា ១: កិច្ចការពារសិទ្ធិអ្នកនិពន្ធ

មាត្រា ២: កិច្ចការពារដែលអនុសញ្ញាផ្តល់ឱ្យ និយមន័យនៃប្រព្រឹត្តកម្មជាតិ

មាត្រា ៣: និយមន័យ: (ក)អ្នកសម្តែង (ខ)ហ្វូណូក្រាម (គ)ផលិតករហ្វូណូក្រាម (ឃ)ការបោះពុម្ពផ្សាយ (ង)ការផលិតឡើងវិញ (ច)ទូរផ្សាយ (ឆ)ការផ្សាយតាមទូរផ្សាយឡើងវិញ

មាត្រា ៤: ការសម្តែងដែលទទួលបានកិច្ចការពារ: លក្ខខណ្ឌដែលត្រូវការពារចំពោះអ្នកសម្តែង

មាត្រា ៥: ហ្វូណូក្រាមដែលទទួលបានកិច្ចការពារ: ១.លក្ខខណ្ឌដែលត្រូវការពារចំពោះផលិតករហ្វូណូក្រាម ២. ការចតផ្សាយស្របពេលជាមួយគ្នា ៣.អំណាចដើម្បីដកចេញលក្ខណៈវិនិច្ឆ័យមួយចំនួន

មាត្រា ៦: ទូរផ្សាយដែលទទួលបានកិច្ចការពារ: ១.លក្ខខណ្ឌដែលត្រូវការពារចំពោះអង្គភាពទូរផ្សាយ ២. អំណាចដើម្បីធ្វើឧរក្សាសិទ្ធិ

មាត្រា ៧: កិច្ចការពារអប្បរមាចំពោះអ្នកសម្តែង:១.សិទ្ធិពិសេស ២.ទំនាក់ទំនងរវាងអ្នកសម្តែងនិងអង្គភាពទូរផ្សាយ

មាត្រា ៨: អ្នកសម្តែងរួមគ្នា

មាត្រា ៩: សិល្បៈករផ្សេងៗនិងសិល្បៈករសៀក

មាត្រា១០: សិទ្ធិផលិតឡើងវិញរបស់ផលិតករហ្វូណូក្រាម

មាត្រា១១: លក្ខខណ្ឌទម្រង់នៃហ្វូណូក្រាម

មាត្រា១២: ការប្រើប្រាស់បន្ទាប់បន្សំនៃហ្វូណូក្រាម

មាត្រា១៣: សិទ្ធិអប្បរមានៃអង្គភាពទូរផ្សាយ

មាត្រា១៤: រយៈពេលអប្បរមានៃកិច្ចការពារ


---

* មាតិកានេះត្រូវបានបន្ថែមដើម្បីជួយសម្រួលអ្នកអាន។ មាតិកានេះមិនមានក្នុងអត្ថបទដើមនៃអនុសញ្ញាឡើយ។

មាត្រា១៥: ការលើកលែងដែលបានអនុញ្ញាតៈ ១.ការកម្រិតជាក់លាក់ ២.ភាពសមមូលទៅនឹងសិទ្ធិអ្នកនិពន្ធ

មាត្រា១៦: ខរក្សាសិទ្ធិ

មាត្រា១៧: ប្រទេសមួយចំនួនដែលអនុវត្តតែលក្ខណៈវិនិច្ឆ័យនៃ"ការថតបញ្ចូល"

មាត្រា១៨: ការដកខរក្សាសិទ្ធិ

មាត្រា១៩: សិទ្ធិអ្នកសម្តែងក្នុងខ្សែភាពយន្ត

មាត្រា២០: អប្រតិសកម្ម

មាត្រា២១: កិច្ចការពារតាមមធ្យោបាយផ្សេងទៀត

មាត្រា២២: កិច្ចព្រមព្រៀងពិសេស

មាត្រា២៣: ការចុះហត្ថលេខានិងការតម្កល់

មាត្រា២៤: ការក្លាយជាភាគីនៃអនុសញ្ញា

មាត្រា២៥: ការចូលជាធរមាន

មាត្រា២៦: ការអនុវត្តអនុសញ្ញាតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ

មាត្រា២៧: ការអនុវត្តអនុសញ្ញាក្នុងដែនដីមួយចំនួន

មាត្រា២៨: ការប្រកាសដកខ្លួនចេញពីអនុសញ្ញា

មាត្រា២៩: ការកែប្រែអនុសញ្ញា

មាត្រា៣០: ការដោះស្រាយវិវាទ

មាត្រា៣១: ការកម្រិតខរក្សាសិទ្ធិ

មាត្រា៣២: គណៈកម្មាធិការអន្តររដ្ឋាភិបាល

មាត្រា៣៣: ភាសា

មាត្រា៣៤: សេចក្តីជូនដំណឹង

ដោយមានចេតនា ការពារសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយរដ្ឋហត្ថលេខីទាំងឡាយ

បានយល់ព្រមគ្នាដូចខាងក្រោមៈ

## មាត្រា១

### [កិច្ចការពារសិទ្ធិអ្នកនិពន្ធ*]

កិច្ចការពារដែលផ្តល់ឱ្យតាមអនុសញ្ញានេះ ត្រូវរក្សាដដែលនិងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់កិច្ចការពារសិទ្ធិអ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រនិងសិល្បៈឡើយ។ ដូច្នេះបទប្បញ្ញត្តិនៃអនុសញ្ញានេះមិនអាចត្រូវបកស្រាយ ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចការពារនេះឡើយ។

## មាត្រា២

### [កិច្ចការពារដែលអនុសញ្ញាផ្តល់ឱ្យ និយមន័យនៃប្រព្រឹត្តកម្មជាតិ]

១. ក្នុងគោលបំណងនៃអនុសញ្ញានេះ ប្រព្រឹត្តកម្មជាតិត្រូវមានន័យថាជាប្រព្រឹត្តកម្មដែលបានផ្តល់ឱ្យដោយច្បាប់ជាតិនៃរដ្ឋហត្ថលេខីដែលបានអះអាងឱ្យមានកិច្ចការពារៈ

(ក) ចំពោះអ្នកសម្តែងដែលជាពលរដ្ឋរបស់ខ្លួនចំពោះការសម្តែងដែលបានផ្សាយតាមទូរផ្សាយ ឬដែលបានថតបញ្ចូលជាលើកដំបូង នៅលើដែនដីរបស់ខ្លួន

(ខ) ចំពោះផលិតករហ្វូណូក្រាមដែលជាពលរដ្ឋរបស់ខ្លួន ចំពោះហ្វូណូក្រាមដែលបានថតបញ្ចូលឬបានថតផ្សាយលើកដំបូងនៅលើដែនដីរបស់ខ្លួន

(គ) ចំពោះអង្គភាពទូរផ្សាយដែលមានទីស្នាក់ការនៅក្នុងដែនដីរបស់ខ្លួន ចំពោះទូរផ្សាយដែលបានផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងក្នុងដែនដីរបស់ខ្លួន។

២. ប្រព្រឹត្តកម្មជាតិ នឹងក្លាយជាកម្មវត្ថុនៃកិច្ចការពារដែលបានធានាយ៉ាងជាក់លាក់ ហើយជាកម្មវត្ថុនៃការកម្រិតយ៉ាងជាក់លាក់ដូចមានចែងក្នុងអនុសញ្ញានេះ។

## មាត្រា៣

### [និយមន័យៈ (ក)អ្នកសម្តែង (ខ)ហ្វូណូក្រាម (គ)ផលិតករហ្វូណូក្រាម (ឃ)ការបោះពុម្ពផ្សាយ (ង)ការផលិតឡើងវិញ (ច)ទូរផ្សាយ (ឆ)ការផ្សាយតាមទូរផ្សាយឡើងវិញ]

ក្នុងគោលបំណងនៃអនុសញ្ញានេះៈ

(ក) "អ្នកសម្តែង" ជាសិល្បៈករ អ្នកចម្រៀង តន្ត្រីករ អ្នករបាំ និងបុគ្គលផ្សេងទៀតដែលដើរតួ ច្រៀង សូត្រ ថ្លែងជំទាស់ សម្តែងតួ ឬសម្តែងស្នាដៃអក្សរសាស្ត្រឬសិល្បៈផ្សេងទៀត

(ខ) "ហ្វូណូក្រាម" មានន័យថាជាការថតបញ្ចូលសម្លេងដោយផ្តាច់មុខនូវសម្លេនានានៃការសម្តែង ឬសម្លេងផ្សេងទៀត

(គ) "ផលិតករហ្វូណូក្រាម" មានន័យថាជារូបវន្តបុគ្គលឬនីតិបុគ្គលដែល ថតបញ្ចូលជាលើកដំបូងនូវសម្លេងនៃការសម្តែងឬសម្លេងផ្សេងទៀត

---

* មាត្រាទាំងឡាយត្រូវបានដាក់ចំណងជើងដើម្បីស្រួលរកអត្ថសញ្ញាណកម្ម។ ក្នុងអត្ថបទដែលចុះហត្ថលេខាគ្មានចំណងជើងទេ។

(ឃ) "ការបោះពុម្ពផ្សាយ" មានន័យថា ជាការផ្តល់ឱ្យសាធារណៈជននូវច្បាប់ចម្លងនៃហ្វូណូក្រាមក្នុងបរិមាណសមរម្យ

(ង) "ការផលិតឡើងវិញ" មានន័យថាជាការបង្កើតច្បាប់ចម្លងមួយឬច្រើននៃការថតបញ្ចូល

(ច) "ទូរផ្សាយ" មានន័យថា ជាការផ្សាយតាមមធ្យោបាយឥតខ្សែដើម្បីឱ្យសាធារណៈជនទទួលបាននូវសម្លេង ឬរូបភាពនិងសម្លេង

(ឆ) "ការផ្សាយតាមទូរផ្សាយឡើងវិញ" មានន័យថា ជាការផ្សាយតាមទូរផ្សាយស្របពេលជាមួយគ្នាដោយអង្គភាពទូរផ្សាយមួយ ចំពោះការផ្សាយរបស់អង្គភាពទូរផ្សាយផ្សេងទៀត។

## មាត្រា៤

## [ការសម្តែងដែលទទួលបានកិច្ចការពារៈ លក្ខខណ្ឌដែលត្រូវការពារចំពោះអ្នកសម្តែង]

រដ្ឋហត្ថលេខីនីមួយៗត្រូវផ្តល់ប្រព្រឹត្តកម្មជាតិចំពោះអ្នកសម្តែង ប្រសិនបើលក្ខខណ្ឌណាមួយដូចខាងក្រោមបានបំពេញៈ

(ក) ការសម្តែងដែលបានប្រព្រឹត្តឡើងនៅក្នុងរដ្ឋហត្ថលេខីផ្សេងទៀត

(ខ) ការសម្តែងដែលបានថតបញ្ចូលជាហ្វូណូក្រាមដែលទទួលបានកិច្ចការពារ តាមមាត្រា៥នៃអនុសញ្ញានេះ

(គ) ការសម្តែងដែលមិនទាន់បានថតបញ្ចូលក្នុងហ្វូណូក្រាម ប៉ុន្តែបានផ្សព្វផ្សាយតាមទូរផ្សាយដែលទទួលបានកិច្ចការពារតាមមាត្រា៦នៃអនុសញ្ញានេះ។

## មាត្រា៥

## [ហ្វូណូក្រាមដែលទទួលបានកិច្ចការពារៈ ១.លក្ខខណ្ឌដែលត្រូវការពារ ចំពោះផលិតករហ្វូណូក្រាម ២. ការថតផ្សាយស្របពេលជាមួយគ្នា ៣.អំណាចដើម្បីដកចេញលក្ខណៈវិនិច្ឆ័យមួយចំនួន]

១. រដ្ឋហត្ថលេខីនីមួយៗត្រូវផ្តល់ប្រព្រឹត្តកម្មជាតិចំពោះផលិតករហ្វូណូក្រាម ប្រសិនបើលក្ខខណ្ឌណាមួយដូចខាងក្រោមបានបំពេញៈ

(ក) ផលិតករហ្វូណូក្រាម ជាពលរដ្ឋនៃរដ្ឋហត្ថលេខីផ្សេងទៀត(លក្ខណៈវិនិច្ឆ័យនៃសញ្ជាតិ)

(ខ) ការថតបញ្ចូលសម្លេងជាលើកដំបូង នៅក្នុងរដ្ឋហត្ថលេខីផ្សេងទៀត(លក្ខណៈវិនិច្ឆ័យនៃការថតបញ្ចូល)

(គ) ហ្វូណ្វាក្រាមដែលថតផ្សាយជាលើកដំបូងនៅក្នុងរដ្ឋហត្ថលេខីផ្សេងទៀត(លក្ខ-ណៈវិនិច្ឆ័យនៃការថតផ្សាយ)។

២. ប្រសិនបើហ្វូណូក្រាមបានថតផ្សាយជាលើកដំបូង នៅក្នុងរដ្ឋដែលមិនមែនជារដ្ឋហត្ថលេខី ប៉ុន្តែប្រសិនបើហ្វូណូក្រាមនោះត្រូវបានថតផ្សាយផងដែរ ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃនៃការថតផ្សាយជាលើកដំបូងរបស់ខ្លួន ក្នុងរដ្ឋហត្ថលេខីមួយ(ការថតផ្សាយស្របពេលជាមួយគ្នា) ហ្វូណូក្រាមនោះត្រូវចាត់ទុកថាបានថតផ្សាយជាលើកដំបូងនៅក្នុងរដ្ឋហត្ថលេខីនេះ។

៣. តាមរយៈសេចក្តីជូនដំណឹងដែលដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ រដ្ឋហត្ថលេខីណាមួយអាចប្រកាសថា ខ្លួននឹងមិនអនុវត្តលក្ខណៈវិនិច្ឆ័យនៃការថតផ្សាយ ឬលក្ខណៈវិនិច្ឆ័យនៃការថតបញ្ចូលផ្សេងទៀត។ សេចក្តីជូនដំណឹងនេះអាចដាក់ក្នុងពេលឬតាមពេលបន្ទាប់ណាមួយក៏បាននៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក។ ក្នុងករណីចុងក្រោយសេចក្តីជូនដំណឹងនឹងមានអានុភាពអនុវត្តក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីបានដាក់។

## មាត្រា៦

## [ទូរផ្សាយដែលទទួលបានកិច្ចការពារៈ ១.លក្ខខណ្ឌដែលត្រូវការពារចំពោះអង្គភាពទូរផ្សាយ ២. អំណាចដើម្បីធ្វើខរក្សាសិទ្ធិ]

១. រដ្ឋហត្ថលេខីនីមួយៗត្រូវផ្តល់ប្រព្រឹត្តកម្មជាតិចំពោះអង្គភាពទូរផ្សាយ ប្រសិនបើលក្ខខណ្ឌណាមួយដូចខាងក្រោមបានបំពេញៈ

(ក) ទីស្នាក់ការរបស់អង្គភាពទូរផ្សាយមានទីតាំងនៅក្នុងរដ្ឋហត្ថលេខីផ្សេងទៀត

(ខ) ទូរផ្សាយ ដែលបានផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងនៅក្នុងរដ្ឋហត្ថលេខីផ្សេងទៀត។

២. តាមរយៈសេចក្តីជូនដំណឹងដែលដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ រដ្ឋហត្ថលេខីណាមួយអាចប្រកាសថា ខ្លួននឹងការពារការផ្សាយលុះត្រាតែទីស្នាក់ការរបស់អង្គភាពទូរផ្សាយមានទីតាំងក្នុងរដ្ឋហត្ថលេខីផ្សេងទៀត ហើយដែលបានផ្សាយចេញពីឧប-ករណ៍ផ្សាយដែលមានទីតាំងក្នុងរដ្ឋហត្ថលេខីមួយនេះ។ សេចក្តីជូនដំណឹងនេះអាចដាក់ក្នុងពេលឬតាមពេលបន្ទាប់ណាមួយក៏បាននៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក។ ក្នុងករណីចុងក្រោយសេចក្តីជូនដំណឹងនឹងមានអានុភាពអនុវត្តក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីបានដាក់។

## មាត្រា៧

## [កិច្ចការពារអប្បរមាចំពោះអ្នកសម្តែង:១.សិទ្ធិពិសេស ២.ទំនាក់ទំនងរវាងអ្នកសម្តែងនិងអង្គភាពទូរផ្សាយ]

១. កិច្ចការពារអ្នកសម្តែងដូចមានចែងក្នុងអនុសញ្ញានេះត្រូវរាប់បញ្ចូលទាំងលទ្ធភាពនៃការការពារ:

(ក) ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈ នៃការសម្តែងរបស់ខ្លួនដោយគ្មានការអនុញ្ញាត លើកលែងតែការសម្តែងដែលប្រើប្រាស់ក្នុងការផ្សាយតាមទូរ-ផ្សាយឬផ្សព្វផ្សាយជាសាធារណៈនោះ ជាការសម្តែងដែលបានផ្សាយតាមទូរផ្សាយរួចហើយ ឬជាការសម្តែងដែលបង្កើតចេញពីការថតបញ្ចូល។

(ខ) ការថតបញ្ចូលការសម្តែងដែលមិនទាន់បានថតបញ្ចូល ដោយគ្មានការអនុញ្ញាត

(គ) ការផលិតឡើងវិញនៃការថតបញ្ចូលការសម្តែងរបស់ខ្លួន ដោយគ្មានការអនុ-ញ្ញាត:

(i) ប្រសិនបើការថតបញ្ចូលដើមនោះបានបង្កើតដោយគ្មានការអនុញ្ញាត

(ii) ប្រសិនបើការផលិតឡើងវិញ ដែលបង្កើតក្នុងគោលបំណងផ្សេងពីអ្វីដែលអ្នកសម្តែងបានអនុញ្ញាត

(iii) ប្រសិនបើការថតបញ្ចូលដើមនោះ បានបង្កើតអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៥ ហើយការផលិតឡើងវិញបានបង្កើតក្នុងគោលបំណងផ្សេងពីអ្វីដែលមានចែងក្នុងបទប្បញ្ញត្តិទាំងនោះ។

២.

(១) ប្រសិនបើការផ្សាយតាមទូរផ្សាយមានការអនុញ្ញាតពីអ្នកសម្តែង ច្បាប់ជាតិរបស់រដ្ឋហត្ថលេខីដែលបានអះអាងឱ្យការពារ ត្រូវកម្រិតកិច្ចការពារទល់នឹងការផ្សាយតាមទូរផ្សាយឡើងវិញ ការថតបញ្ចូលក្នុងបំណងផ្សាយតាមទូរផ្សាយ និងការផលិតឡើងវិញនៃការថតបញ្ចូលនេះក្នុងបំណងផ្សាយតាមទូរផ្សាយ។

(២) រយៈពេលនិងលក្ខខណ្ឌទាំងឡាយដែលគ្រប់គ្រង ការប្រើប្រាស់ដោយអង្គ-ភាពទូរផ្សាយចំពោះការថតបញ្ចូលដែលបង្កើតឡើងក្នុងបំណងផ្សាយតាមទូរផ្សាយ ត្រូវបានកំណត់ដោយអនុលោមតាមច្បាប់ជាតិរបស់រដ្ឋហត្ថលេខីដែលបានអះអាងឱ្យការពារ។

(៣) ប៉ុន្តែ ច្បាប់ជាតិដែលយោងតាមអនុកថាខណ្ឌ(១)និង(២)នៃកថាខណ្ឌនេះមិនត្រូវបដិសេធន៍សមត្ថភាពអ្នកសម្តែង ក្នុងការគ្រប់គ្រងទំនាក់ទំនងរបស់ខ្លួនជាមួយអង្គភាពទូរផ្សាយ តាមកិច្ចសន្យាឡើយ។

**មាត្រា៨**

**[អ្នកសម្តែងរួមគ្នា]**

តាមច្បាប់ជាតិនិងបទបញ្ជាទាំងឡាយរបស់ខ្លួន រដ្ឋហត្ថលេខីណាមួយអាចបញ្ជាក់ពីរបៀបដែលអ្នកសម្តែងនឹងត្រូវតំណាង ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ប្រសិនបើអ្នកសម្តែងខ្លះបានចូលរួមក្នុងការសម្តែងដូចគ្នា។

**មាត្រា៩**

**[សិល្បៈករផ្សេងៗនិងសិល្បៈករសៀក]**

តាមច្បាប់ជាតិនិងបទបញ្ជារបស់ខ្លួន រដ្ឋហត្ថលេខីអាចពង្រីកកិច្ចការពារ ដែលមានចែងក្នុងអនុញ្ញានេះ ចំពោះសិល្បៈករដែលមិនបានសម្តែងស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។

**មាត្រា១០**

**[សិទ្ធិផលិតឡើងវិញរបស់ផលិតករហ្វូណូក្រាម]**

ផលិតករហ្វូណូក្រាមត្រូវទទួលបានសិទ្ធិក្នុងការអនុញ្ញាត ឬហាមឃាត់ដោយផ្ទាល់ឬប្រយោល ក្នុងការផលិតហ្វូណូក្រាមរបស់ខ្លួនឡើងវិញ។

**មាត្រា១១**

**[លក្ខខណ្ឌទម្រង់នៃហ្វូណូក្រាម]**

ជាលក្ខខណ្ឌនៃកិច្ចការពារសិទ្ធិផលិតករហ្វូណូក្រាម ឬសិទ្ធិអ្នកសម្តែង ឬសិទ្ធិរបស់អ្នកទាំងពីរចំពោះហ្វូណូក្រាម តាមច្បាប់ជាតិរបស់ខ្លួន ប្រសិនបើភាគីហត្ថលេខីមួយទាមទារឱ្យគោរពលក្ខខណ្ឌទម្រង់ លក្ខខណ្ឌទម្រង់នេះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើច្បាប់ការចម្លងលក្ខណៈពាណិជ្ជកម្មនៃហ្វូណូក្រាមដែលចតផ្សាយ ឬនៅក្នុងគំរបហ្វូណូក្រាមនោះមានសម្គាល់នៃនិមិត្តសញ្ញា(P) អមដោយឆ្នាំនៃការចតផ្សាយជាលើកដំបូង ដែលសរសេរតាមរបៀប ដែលអាចសម្គាល់បានយ៉ាងសមរម្យអំពីការទាមទារឱ្យការពារ។ ប្រសិនបើច្បាប់ចម្លងឬគំរបហ្វូណូក្រាមមិនសម្គាល់បាននូវ ផលិតករ ឬអ្នកទទួលអាជ្ញាប័ណ្ណពីផលិតករ (ដោយមានដាក់ឈ្មោះរបស់គាត់ ម៉ាក ឬការសម្គាល់សមរម្យផ្សេងទៀត) កំណត់សម្គាល់ត្រូវមានផងដែរនូវ ឈ្មោះម្ចាស់សិទ្ធិ ឈ្មោះផលិតករ ហើយជាងនេះទៀតប្រសិនបើច្បាប់ចម្លងឬគំរបមិនបញ្ជាក់ពីអ្នកសម្តែងសំខាន់ៗ កំណត់សម្គាល់ក៏ត្រូវដាក់ផងដែរនូវឈ្មោះរបស់បុគ្គលដែលកាន់កាប់សិទ្ធិអ្នកសម្តែងទាំងនេះ ក្នុងប្រទេសដែលបានធ្វើការចតបញ្ចូល។

## មាត្រា១២

## [ការប្រើប្រាស់បន្ទាប់បន្សំនៃហ្វូណូក្រាម]

ប្រសិនបើហ្វូណូក្រាមបានថតផ្សាយក្នុងបំណងអាជីវកម្ម ឬការផលិតឡើងវិញនៃហ្វូណូក្រាមនេះ បានប្រើប្រាស់ដោយផ្ទាល់ក្នុងការផ្សាយតាមទូរផ្សាយឬការផ្សព្វផ្សាយជាសាធារណៈណាមួយ លាភការសមរម្យតែមួយលើកគត់ដែលត្រូវបង់ដោយអ្នកប្រើប្រាស់ ដល់អ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬក៏បុគ្គលទាំងពីរនេះ។ បើគ្មានកិច្ចព្រមព្រៀងរវាងភាគីទាំងនេះទេ ច្បាប់ជាតិអាចកំណត់លក្ខខណ្ឌនៃការបែងចែកលាភការទាំងនេះ។

## មាត្រា១៣

## [សិទ្ធិអប្បរមានៃអង្គភាពទូរផ្សាយ]

អង្គភាពទូរផ្សាយត្រូវទទួលបានសិទ្ធិក្នុងការអនុញ្ញាតឬហាមឃាត់:

(ក) ការផ្សាយតាមទូរផ្សាយឡើងវិញនូវការផ្សាយរបស់ខ្លួន

(ខ) ការថតបញ្ចូលការផ្សាយរបស់ខ្លួន

(គ) ការផលិតឡើងវិញ:

(i) នូវការថតបញ្ចូលការផ្សាយរបស់ខ្លួន ដោយគ្មានការអនុញ្ញាត

(ii) ការថតបញ្ចូលការផ្សាយរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃមាត្រា១៥ ប្រសិនបើការផលិតឡើងវិញធ្វើឡើងក្នុងបំណងខុសពីបញ្ញត្តិដែលមានកំណត់ក្នុងបទប្បញ្ញត្តិទាំងនេះ។

(ឃ)ការផ្សព្វផ្សាយជាសាធារណៈនៃការផ្សាយតាមទូរទស្សន៍របស់ខ្លួន ប្រសិនបើការផ្សព្វផ្សាយនេះបានធ្វើឡើងក្នុងទីតាំងដែលបើកជូនសាធារណៈជន ជាថ្នូរនៃការបង់កម្រៃចូល។ ច្បាប់ជាតិរបស់រដ្ឋដែលបានអះអាងឱ្យការពារសិទ្ធិ ជាអ្នកកំណត់លក្ខខណ្ឌនៃការអនុវត្តនេះ។

## មាត្រា១៤

## [រយៈពេលអប្បរមានៃកិច្ចការពារ]

រយៈពេលនៃកិច្ចការពារដែលអនុសញ្ញានេះផ្តល់ឱ្យ ត្រូវមានយ៉ាងហោចណាស់២០(ម្ភៃ)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំដែល:

(ក) មានការថតបញ្ចូល ចំពោះហ្វូណូក្រាមនិងចំពោះការសម្តែងដែលបានថតបញ្ចូលក្នុងហ្វូណូក្រាម

(ខ) មានការសម្តែង ចំពោះការសម្តែងដែលមិនទាន់បានថតបញ្ចូលក្នុងហ្វូណូក្រាម

(គ) មានការផ្សាយតាមទូរផ្សាយ ចំពោះការផ្សាយនានា។

## មាត្រា១៥
## [ការលើកលែងដែលបានអនុញ្ញាត: ១.ការកម្រិតជាក់លាក់ ២.ភាពសមមូល ទៅនឹងសិទ្ធិអ្នកនិពន្ធ]

១. ក្នុងច្បាប់ជាតិនិងបទបញ្ញារបស់ខ្លួន រដ្ឋហត្ថលេខីណាមួយអាចចែងអំពីការលើកលែងចំពោះកិច្ចការពារដែលធានាដោយអនុសញ្ញានេះចំពោះ:

(ក) ការប្រើប្រាស់លក្ខណ:ឯកជន

(ខ) ការប្រើប្រាស់សេចក្តីដកស្រង់ខ្លីៗ ទាក់ទងនឹងសេចក្តីរាយការណ៍បច្ចុប្បន្នភាព

(គ) ការថតបញ្ចូលបណ្តោះអាសន្ន ដោយអង្គភាពទូរផ្សាយណាមួយតាមរយៈឧបករណ៍ផ្ទាល់របស់ខ្លួននិងសម្រាប់តែការផ្សាយផ្ទាល់ខ្លួនប៉ណ្ណោះ។

(ឃ) ការប្រើប្រាស់សម្រាប់តែគោលបំណងនៃ ការបង្រៀនឬការស្រាវជ្រាវវិទ្យាសាស្រ្ត។

២. ដោយមិនគិតដល់កថាខណ្ឌ១នៃមាត្រានេះ ក្នុងច្បាប់ជាតិនិងបទបញ្ញារបស់ខ្លួនរដ្ឋហត្ថលេខីណាមួយអាចចែងឱ្យមានការកម្រិតដូចគ្នា ចំពោះកិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ដូចដែលប្រទេសនេះបានចែងក្នុងច្បាប់ជាតិនិងបទបញ្ញារបស់ខ្លួន ទាក់ទងនឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធស្នាដៃអក្សរសាស្រ្តនិងសិល្ប:។ ប៉ុន្តែអាចចែងអំពីអាជ្ញាប័ណ្ណបញ្ញាបានលុះត្រាតែចែងស្របនឹងអនុសញ្ញានេះ។

## មាត្រា១៦
## [ខរក្សាសិទ្ធិ]

១. នៅពេលក្លាយជាភាគីនៃអនុសញ្ញានេះ រដ្ឋណាមួយត្រូវចងភ្ជាប់ដោយកាតព្វកិច្ចទាំងឡាយហើយត្រូវទទួលយកនូវអត្ថប្រយោជន៍ទាំងឡាយពីអនុសញ្ញានេះផងដែរ។ ប៉ុន្តែតាមសេចក្តីជូនដំណឹងដែលជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ប្រទេសណាមួយនាពេលណាក៏បាន អាចប្រកាសថា:

(ក) ចំពោះមាត្រា១២:

(i) ថាខ្លួនមិនអនុវត្តបទប្បញ្ញត្តិនៃមាត្រានេះទេ

(ii) ថាខ្លួនមិនអនុវត្តបទប្បញ្ញត្តិនៃមាត្រានេះទេ ចំពោះការប្រើប្រាស់មួយចំនួន

(iii) ថាខ្លួនមិនអនុវត្តមាត្រានេះទេ ចំពោះហ្វូណូក្រាម ដែលផលិតករមិនមែនជាពលរដ្ឋរបស់រដ្ឋហត្ថលេខីផ្សេងទៀត

(iv) ចំពោះហ្វូណូក្រាម ដែលផលិតករជាពលរដ្ឋរបស់រដ្ឋហត្ថលេខីផ្សេងទៀត ខ្លួននឹងកម្រិតវិសាលភាពនិងរយៈពេលនៃកិច្ចការពារដូចមានចែងក្នុងមាត្រានេះ ដែលរដ្ឋហត្ថលេខីផ្សេងទៀតនេះ ផ្ដល់កិច្ចការពារចំពោះហ្វូណូក្រាមដែលបានថតបញ្ចូលជាលើកដំបូងដោយពលរដ្ឋនៃរដ្ឋដែលបានធ្វើសេចក្ដីប្រកាស។ ប៉ុន្តែការណ៍ដែលរដ្ឋហត្ថលេខី ដែលផលិតករជាពលរដ្ឋរបស់ខ្លួនមិនការពារអ្នកទទួលផលណាមួយ ដូចគ្នានឹងរដ្ឋដែលធ្វើសេចក្ដីប្រកាស មិនត្រូវចាត់ទុកថាជាការខុសគ្នាចំពោះវិសាលភាពនៃកិច្ចការពារឡើយ។

(ខ) ចំពោះមាត្រា១៣ ខ្លួននឹងមិនអនុវត្តចំនុច(ឃ)នៃមាត្រានេះ។ ប្រសិនបើរដ្ឋហត្ថលេខីធ្វើសេចក្ដីប្រកាស រដ្ឋហត្ថលេខីផ្សេងទៀតគ្មានកាតព្វកិច្ចផ្ដល់សិទ្ធិដោយយោងតាមមាត្រា១៣ចំនុច(ឃ) ដល់អង្គភាពទូរផ្សាយដែលមានទីស្នាក់ការនៅក្នុងរដ្ឋនេះ។

២. ប្រសិនបើសេចក្ដីជូនដំណឹងយោងតាមកថាខណ្ឌ១នៃមាត្រានេះ បានធ្វើបន្ទាប់ពីកាលបរិច្ឆេទតម្កល់លិខិតតុបករណ៍នៃការផ្ដល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក សេចក្ដីប្រកាសនេះនឹងមានអានុភាពអនុវត្តក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីបានតម្កល់។

## មាត្រា១៧

## [ប្រទេសមួយចំនួនដែលអនុវត្តតែលក្ខណៈវិនិច្ឆ័យនៃ"ការថតបញ្ចូល"]

ត្រឹមថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៦១ រដ្ឋណាមួយដែលផ្ដល់កិច្ចការពារចំពោះផលិតករហ្វូណូក្រាមដោយយោងតែទៅលើលក្ខណៈវិនិច្ឆ័យនៃការថតបញ្ចូល តាមរយៈសេចក្ដីជូនដំណឹងដែលដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នៅពេលផ្ដល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក អាចប្រកាសថាខ្លួននឹងអនុវត្តលក្ខណៈវិនិច្ឆ័យនៃការថតបញ្ចូលតែប៉ុណ្ណោះក្នុងគោលបំណងនៃមាត្រា៥ និងលក្ខណៈវិនិច្ឆ័យនៃការថតបញ្ចូលជំនួសឱ្យលក្ខណៈវិនិច្ឆ័យនៃសញ្ជាតិក្នុងគោលបំណងនៃកថាខណ្ឌ១(ក)(iii)និង(iv)នៃមាត្រា១៦។

## មាត្រា១៨

## [ការដកខរក្សាសិទ្ធិ]

រដ្ឋណាមួយដែលតម្កល់សេចក្ដីជូនដំណឹង តាមកថាខណ្ឌ៣នៃមាត្រា៥ កថាខណ្ឌ២នៃមាត្រា៦ កថាខណ្ឌ១នៃមាត្រា១៦ឬមាត្រា១៧ តាមរយៈសេចក្ដីជូនដំណឹងថ្មីមួយដែលដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ អាចបន្ថយវិសាលភាពនិងដកសេចក្ដីជូនដំណឹងចេញបាន។

## មាត្រា១៩

## [សិទ្ធិអ្នកសម្តែងក្នុងខ្សែភាពយន្ត]

ដោយមិនគិតពីបទប្បញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ មាត្រា៧មិនត្រូវយកមកអនុវត្តឡើយ នៅពេលដែលអ្នកសម្តែងបានអនុញ្ញាតដើម្បីឱ្យថតបញ្ចូល នូវការសម្តែងរបស់ខ្លួនក្នុងការថតបញ្ចូលជារូបភាព ឬជាសោតទស្សន៍។

## មាត្រា២០

## [អប្រតិសកម្ម]

១. អនុសញ្ញានេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិទាំងឡាយដែលទទួលបានក្នុងរដ្ឋហត្ថលេខីណាមួយ មុនកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ ចំពោះរដ្ឋនេះ។

២. គ្មានរដ្ឋហត្ថលេខីណាមួយ ត្រូវបានជាប់កាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ចំពោះការសម្តែង ឬការផ្សាយដែលបានធ្វើឡើង ឬចំពោះហ្វូណូក្រាមដែលបានថតបញ្ចូល មុនកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ ចំពោះរដ្ឋនេះ។

## មាត្រា២១

## [កិច្ចការពារតាមមធ្យោបាយផ្សេងទៀត]

កិច្ចការពារដូចមានចែងក្នុងអនុសញ្ញានេះមិនត្រូវប៉ះពាល់ដល់ កិច្ចការពារផ្សេងទៀតដែលបានផ្តល់ចំពោះ អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយឡើយ។

## មាត្រា២២

## [កិច្ចព្រមព្រៀងពិសេស]

រដ្ឋហត្ថលេខីទាំងឡាយ រក្សាសិទ្ធិដើម្បីចុះកិច្ចព្រមព្រៀងពិសេសរវាងគ្នា ឱ្យតែកិច្ចព្រមព្រៀងនេះផ្តល់ឱ្យ អ្នកសម្តែង ផលិតករហ្វូណូក្រាម ឬអង្គភាពទូរផ្សាយនូវសិទ្ធិច្រើនជាងសិទ្ធិដែលបានផ្តល់ឱ្យដោយអនុសញ្ញា ឬឱ្យតែកិច្ចព្រមព្រៀងនេះមានបទប្បញ្ញត្តិផ្សេងទៀតដែលមិនផ្ទុយនឹងអនុសញ្ញានេះ។

## មាត្រា២៣

## [ការចុះហត្ថលេខានិងការតម្កល់]

អនុសញ្ញានេះត្រូវតម្កល់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ អនុសញ្ញានេះនៅតែបើកចំហរសម្រាប់ការចុះហត្ថលេខា រហូតដល់ថ្ងៃទី៣០ខែមិថុនាឆ្នាំ១៩៦២ ដោយរដ្ឋណាមួយដែលបានអញ្ជើញចូលរួមក្នុងសន្និសីទការទូតស្តីពីកិច្ចការពារអន្តរជាតិចំពោះ អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ដែលជាភាគីនៃអនុសញ្ញាជាសកលស្តីពីសិទ្ធិអ្នកនិពន្ធ ឬជាសមាជិកនៃសហភាពអន្តរជាតិស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។

## មាត្រា២៤

## [ការក្លាយជាភាគីនៃអនុសញ្ញា]

១. អនុសញ្ញានេះត្រូវដាក់ឱ្យធ្វើសច្ចាប័នឬទទួលយក ដោយរដ្ឋហត្ថលេខី។

២. អនុសញ្ញានេះនៅតែបើកចំហរសម្រាប់ការចូលជាសមាជិក ដោយរដ្ឋណាមួយដែលបានអញ្ជើញចូលរួមក្នុងសន្និសីទដោយយោងតាមមាត្រា២៣ និងដោយរដ្ឋជាសមាជិកណាមួយរបស់អង្គការសហប្រជាជាតិ ឱ្យតែរដ្ឋនេះជាភាគីនៃអនុសញ្ញាសាកលស្តីពីសិទ្ធិអ្នកនិពន្ធឬជាសមាជិកនៃសហភាពអន្តរជាតិស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។

៣. ការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិកត្រូវធ្វើឡើងតាមការតម្កល់លិខិតតុបករណ៍ ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

## មាត្រា២៥

## [ការចូលជាធរមាន]

១. អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតតុបករណ៍ទី៦(ប្រាំមួយ)នៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក។

២. ហេតុនេះ អនុសញ្ញានេះត្រូវចូលជាធរមានចំពោះរដ្ឋនីមួយៗ ក្នុងរយៈពេល៣(បី) បន្ទាប់ពីកាលបរិច្ឆេទ នៃតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក។

## មាត្រា២៦

## [ការអនុវត្តអនុសញ្ញាតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ]

១. អនុលោមតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន រដ្ឋហត្ថលេខីនីមួយៗសន្យានឹងអនុម័តវិធានការនានាដែលចាំបាច់ដើម្បីធានាការអនុវត្តអនុសញ្ញានេះ។

២. នៅពេលតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិករបស់ខ្លួន រដ្ឋនីមួយៗត្រូវចាត់ចែងផ្តល់អានុភាពទៅឱ្យអនុសញ្ញានេះ ឱ្យស្របទៅនឹងច្បាប់ជាតិរបស់ខ្លួន។

## មាត្រា២៧

## [ការអនុវត្តអនុសញ្ញាក្នុងដែនដីមួយចំនួន]

១. នៅពេលផ្តល់សច្ចាប័ន ការទទួលយកឬការចូលជាសមាជិក ឬតាមពេលណាមួយក្រោយទៀត រដ្ឋណាមួយអាចប្រកាសតាមការជូនដំណឹងទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិថា អនុសញ្ញានេះត្រូវលាតសន្ធឹងលើដែនដីទាំងអស់ឬដែនដីណាមួយ ចំពោះ

ទំនាក់ទំនងអន្តរជាតិដែលខ្លួនទទួលខុសត្រូវ ឱ្យតែអនុសញ្ញាជាសកលស្ដីពីសិទ្ធិអ្នកនិពន្ធ ឬអនុសញ្ញាអន្តរជាតិស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ អនុវត្តលើដែនដីឬដែន-ដីណាមួយពាក់ព័ន្ធ។ សេចក្ដីជូនដំណឹងនេះត្រូវមានអានុភាពអនុវត្តក្នុងរយៈ ពេល៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលទទួលបានសេចក្ដីជូនដំណឹង។

២. សេចក្ដីជូនដំណឹងអនុលោមតាមកថាខណ្ឌ៣នៃមាត្រា៥ កថាខណ្ឌ២នៃមាត្រា៦ កថាខណ្ឌ១នៃមាត្រា១៦ និងមាត្រា១៧និងមាត្រា១៨ អាចត្រូវបានពន្លាតដើម្បីគ្រប់គ្រងលើផ្នែកទាំងអស់ឬផ្នែកណាមួយនៃដែនដីតាមកថាខណ្ឌ១នៃមាត្រានេះ។

## មាត្រា២៨

## [ការប្រកាសដកខ្លួនចេញពីអនុសញ្ញា]

១. រដ្ឋហត្ថលេខីណាមួយអាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ ក្នុងនាមខ្លួនឬក្នុងនាមដែនដីទាំងអស់ ឬក្នុងនាមដែនដីណាមួយតាមមាត្រា២៧។

២. ការប្រកាសដកខ្លួនចេញត្រូវធ្វើឡើង តាមការជូនដំណឹងទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ហើយត្រូវមានអានុភាពអនុវត្តក្នុងរយៈពេល១២(ដប់ពីរ)ខែបន្ទាប់ពីកាលបរិច្ឆេទដែលទទួលបានសេចក្ដីជូនដំណឹង។

៣. សិទ្ធិប្រកាសដកខ្លួនចេញ មិនត្រូវបានអនុវត្តដោយរដ្ឋហត្ថលេខី មុនផុតរយៈពេល៥(ប្រាំ)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញាបានចូលជាធរមាន ចំពោះរដ្ឋនេះ។

៤. រដ្ឋហត្ថលេខីមួយ លែងត្រូវចាត់ទុកជាភាគីនៃអនុសញ្ញានេះបន្តទៅទៀត នៅពេលដែលរដ្ឋនេះមិនមែនជាភាគីនៃអនុសញ្ញាជាសកលស្ដីពីសិទ្ធិអ្នកនិពន្ធ ហើយក៏មិនមែនជាសមាជិកនៃសហភាពអន្តរជាតិស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។

៥. អនុសញ្ញានេះ លែងត្រូវអនុវត្តចំពោះដែនដីណាមួយដូចមានចែងក្នុងមាត្រា២៧បន្តទៅទៀត នៅពេលដែលអនុសញ្ញាជាសកលស្ដីពីសិទ្ធិអ្នកនិពន្ធ ឬអនុសញ្ញាអន្តរជាតិស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈមិនអនុវត្តចំពោះដែនដីនេះ។

## មាត្រា២៩

## [ការកែប្រែអនុសញ្ញា]

១. ៥ឆ្នាំបន្ទាប់ពីអនុសញ្ញានេះបានចូលជាធរមាន តាមរយៈការជូនដំណឹងទៅអគ្គលេ-ខាធិការនៃអង្គការសហប្រជាជាតិ រដ្ឋហត្ថលេខីណាមួយអាចស្នើសុំឱ្យកោះប្រជុំសន្និសីទដើម្បីកែប្រែអនុសញ្ញា។ អគ្គលេខាធិការត្រូវជូនដំណឹងទៅរដ្ឋហត្ថលេខីទាំងអស់អំពីសំ-ណើនេះ។ ក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងដោយអគ្គ-លេខាធិការនៃអង្គការសហប្រជាជាតិ ប្រសិនបើរដ្ឋហត្ថលេខីមិនតិចជាងពាក់កណ្ដាលបាន

ជូនដំណឹងទៅអគ្គលេខាធិការ ពីការព្រមព្រៀងចំពោះសំណើនេះ អគ្គលេខាធិការត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ អគ្គនាយកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងនាយកការិយាល័យសហភាពអន្តរជាតិស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ដែលត្រូវកោះប្រជុំសន្និសីទកែប្រែដោយសហការជាមួយគណៈកម្មាធិការអន្តររដ្ឋាភិបាលដូចមានចែងក្នុងមាត្រា៣២។

២. ការអនុម័តយល់ព្រមលើការកែប្រែណាមួយនៃអនុសញ្ញានេះ ទាមទារឱ្យមានការបោះឆ្នោតយល់ព្រមចំនួន២/៣(ពីរភាគបី) នៃរដ្ឋដែលបានចូលរួមក្នុងសន្និសីទកែប្រែនេះ ឱ្យតែមតិភាគច្រើននេះមានរដ្ឋជាភាគីនៃអនុសញ្ញាចំនួន២/៣(ពីរភាគបី) នៅពេលធ្វើសន្និសីទកែប្រែ ។

៣. នៅពេលដែលមានការអនុម័ត អនុសញ្ញាថ្មីស្តីពីការកែប្រែអនុសញ្ញានេះទាំងមូល ឬដោយផ្នែក ហើយឱ្យតែអនុសញ្ញាថ្មីមិនបានចែងផ្ទុយៈ

(ក) អនុសញ្ញានេះលែងត្រូវបើកចំហរ ដើម្បីផ្តល់សច្ចាប័ន ទទួលយកឬចូលជាសមាជិក ចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញាថ្មីដែលបានកែប្រែ។

(ខ) អនុសញ្ញានេះនៅតែមានសុពលភាពអនុវត្ត ចំពោះទំនាក់ទំនងរវាងរដ្ឋហត្ថលេខីនិងរដ្ឋហត្ថលេខី ឬជាមួយរដ្ឋហត្ថលេខីដែលមិនទាន់ក្លាយជាភាគីនៃអនុសញ្ញាថ្មីដែលបានកែប្រែ។

## មាត្រា៣០

## [ការដោះស្រាយវិវាទ]

វិវាទណាមួយដែលអាចកើតឡើងរវាងរដ្ឋហត្ថលេខី២(ពីរ)ឬច្រើន ទាក់ទងនឹងការបកស្រាយឬការអនុវត្តអនុសញ្ញានេះ ហើយដែលមិនបានដោះស្រាយតាមការចរចាតាមសំណើរបស់ភាគីណាមួយនៃភាគីវិវាទ ត្រូវបានបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិដើម្បីសម្រេច លើកលែងតែភាគីវិវាទព្រមទទួលនូវវិធីដោះស្រាយផ្សេងទៀត។

## មាត្រា៣១

## [ការកម្រិតខរក្សាសិទ្ធិ]

ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃកថាខណ្ឌ៣នៃមាត្រា៥ កថាខណ្ឌ២នៃមាត្រា៦ កថាខណ្ឌ១នៃមាត្រា១៦ និងមាត្រា១៧ អនុសញ្ញានេះមិនអនុញ្ញាតឱ្យមានខរក្សាសិទ្ធិទេ។

## មាត្រា៣២

## [គណៈកម្មាធិការអន្តររដ្ឋាភិបាល]

១. គណៈកម្មាធិការអន្តររដ្ឋាភិបាល ត្រូវបានបង្កើតដើម្បីបំពេញភារៈកិច្ចទាំងឡាយដូចខាងក្រោម:

(ក) សិក្សាលើបញ្ហាទាំងឡាយ ទាក់ទងនឹងការអនុវត្តនិងប្រតិបត្តិការនៃអនុសញ្ញានេះ ហើយ

(ខ) ប្រមូលសំណើសុំនិងរៀបចំសំណុំឯកសារដើម្បីកែប្រែអនុសញ្ញានេះ ប្រសិនបើមាន។

២. គណៈកម្មាធិការត្រូវមានអ្នកតំណាងជារដ្ឋហត្ថលេខីទាំងឡាយ ដែលត្រូវបានជ្រើសរើសតាមការបែកចែកទីតាំងភូមិសាស្ត្រប្រកបដោយសមធម៌។ ចំនួនសមាជិកត្រូវមាន៦(ប្រាំមួយ)រូបប្រសិនបើរដ្ឋហត្ថលេខីមានចំនួន១២(ដប់ពីរ) ឬតិចជាងនេះ ៩(ប្រាំបួន)រូបប្រសិនបើរដ្ឋហត្ថលេខីមានចំនួនពី១៣(ដប់បី)ទៅ ១៨(ដប់ប្រាំបី) ហើយត្រូវមាន១២(ដប់ពីរ)រូបប្រសិនបើ រដ្ឋហត្ថលេខីមានចំនួនច្រើនជាង១៨(ដប់ប្រាំបី)។

៣. គណៈកម្មាធិការត្រូវបានបង្កើតក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុសញ្ញាចូលជាធរមាន តាមរយៈការបោះឆ្នោតដែលរៀបចំក្នុងចំណោមរដ្ឋហត្ថលេខីទាំងឡាយ ដោយរដ្ឋមួយត្រូវមានសម្លេងឆ្នោតមួយ ដោយអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ អគ្គនាយកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ និងនាយកការិយាល័យសហភាពអន្តរជាតិសម្រាប់កិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ដោយអនុលោមតាមវិធាន ដែលបានយល់ព្រមពីមុនដោយរដ្ឋហត្ថលេខីភាគច្រើន។

៤. គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសប្រធាននិងមន្ត្រីរបស់ខ្លួន។ គណៈកម្មាធិការត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវចែងជាពិសេសអំពីការប្រព្រឹត្តទៅនាពេលអនាគតរបស់គណៈកម្មាធិការ និងអំពីរបៀបនៃការជ្រើសរើសសមាជិករបស់ខ្លួននាពេលអនាគតដើម្បីធានាឱ្យមានការផ្លាស់វេនគ្នាក្នុងចំណោមរដ្ឋហត្ថលេខីផ្សេងៗ។

៥. បុគ្គលិកនៃការិយាល័យពលកម្មអន្តរជាតិ បុគ្គលិកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងបុគ្គលិកនៃការិយាល័យសហភាពអន្តរជាតិសម្រាប់កិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ ដែលតែងតាំងដោយអគ្គនាយកនិងនាយកនៃអង្គការទាំងនេះ ជាលេខាធិការដ្ឋាននៃគណៈកម្មាធិការ។

៦. កិច្ចប្រជុំរបស់គណៈកម្មាធិការដែលត្រូវកោះប្រជុំ នៅពេលណាដែលសមាជិករបស់ខ្លួនភាគច្រើនយល់ថាចាំបាច់ ត្រូវធ្វើឡើងជាបន្តបន្ទាប់នៅទីស្នាក់ការ របស់ការិយា

ល័យពលកម្មអន្តរជាតិ របស់អង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងរបស់ការិយាល័យសហភាពអន្តរជាតិសម្រាប់កិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ។

៧. ការចំណាយរបស់សមាជិកទាំងឡាយនៃគណៈកម្មាធិការ ជាបន្ទុករបស់រដ្ឋាភិបាលរៀងៗខ្លួន។

## មាត្រា៣៣

## [ភាសា]

១. អនុសញ្ញានេះ ត្រូវធ្វើឡើងជាភាសាអង់គ្លេស ភាសាបារាំងនិងភាសាអេស្ប៉ាញ។ អត្ថបទទាំងបីមានតម្លៃស្មើៗគ្នា។

២. អត្ថបទផ្លូវការនៃអនុសញ្ញានេះ ត្រូវធ្វើបន្ថែមជាភាសាអាឡឺម៉ង់ ភាសាអ៊ីតាលី និងភាសាព័រទុយហ្កាល់។

## មាត្រា៣៤

## [សេចក្តីជូនដំណឹង]

១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងចំពោះរដ្ឋទាំងឡាយដែលបានអញ្ជើញឱ្យចូលរួមក្នុងសន្និសីទដូចមានចែងក្នុងមាត្រា២៣ និងចំពោះរដ្ឋទាំងអស់ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ហើយក៏ជូនដំណឹងទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ អគ្គនាយកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងនាយកការិយាល័យសហភាពអន្តរជាតិដើម្បីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ :

(ក) អំពីការតម្កល់ លិខិតតុបករណ៍នីមួយៗនៃការផ្តល់សច្ចាប័ន ការទទួលយក ឬការចូលជាសមាជិក

(ខ) អំពីកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ

(គ) អំពីសេចក្តីជូនដំណឹង សេចក្តីប្រកាសឬការជូនព័ត៌មានទាំងអស់ ដែលមានចែងក្នុងអនុសញ្ញានេះ

(ឃ) អំពីការកើតឡើងនៃស្ថានភាពណាមួយ តាមកថាខណ្ឌ៤និង៥នៃមាត្រា២៨។

២. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិក៏ត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ អគ្គនាយកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងនាយកនៃការិយាល័យសហភាពអន្តរជាតិដើម្បីកិច្ចការពារស្នាដៃអក្សរសាស្ត្រ

និងសិល្បៈ អំពីសំណើដែលបានជូនដំណឹងមកខ្លួនតាមមាត្រា២៩ ក៏ដូចជាការជូនព័ត៌មានណាមួយដែលទទួលបានពីរដ្ឋហត្ថលេខីទាំងឡាយទាក់ទងនឹងការកែប្រែអនុសញ្ញា។

ដើម្បីទុកជាសាក្សី ហត្ថលេខីខាងក្រោមដែលត្រូវបានអនុញ្ញាតត្រឹមត្រូវ បានចុះហត្ថលេខាលើអនុញ្ញានេះ។

ធ្វើនៅទីក្រុងរ៉ូម ចុះថ្ងៃទី២៦ខែតុលាឆ្នាំ១៩៦១ ក្នុងអត្ថបទតែមួយជាភាសាអង់គ្លេស ភាសាបារាំង និងភាសាអេស្ប៉ាញ។ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវបញ្ជូនអត្ថបទចម្លងដែលបញ្ជាក់ថាត្រឹមត្រូវ ទៅកាន់រដ្ឋទាំងអស់ដែលបានអញ្ជើញឱ្យចូលរួមក្នុងសន្និសីទតាមមាត្រា២៣ ហើយទៅកាន់រដ្ឋជាសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ ក៏ដូចជាទៅកាន់អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ អគ្គនាយកនៃអង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ និងនាយកនៃការិយាល័យសហភាពអន្តរជាតិដើម្បីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។